# សមាគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY

LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ ០២៧/០៩ ស.ខ.ក.ក.

## លិខិតរំលែកទុក្ខ

**ជូនៈ លោក ស៊ីន ញឿន និងក្មួយប្រុសស្រីនៃគ្រួសារសពលោកស៊ីន ធន ឡឹប**

តាងនាមថ្នាក់ដឹកនាំ សមាជិក សមាជិកា សហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំផ្ទាល់ មានទុក្ខយ៉ាងក្រៀមក្រំ និងសោកស្តាយជាទីបំផុត នៅពេលដែលបានទទួលដំណឹងអំពីមរណភាពរបស់លោក **ស៊ីន ធន ឡឹប** (ហៅ**ស៊ីន យ៉ុយ**) ជាស្ថាបនិក និងជាសមាជិកក្រុមប្រឹក្សាភិបាលសហគមន៍ខ្មែរកម្ពុជាក្រោមទ្វីបអាមេរិកខាងជើង និងប្រទេសកាណាដា កាលពីវេលាម៉ោង៨យប់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩ ក្នុងព្រះជន្មាយុ៦៥ឆ្នាំ ដោយរោគាពាធ។

យើងខ្ញុំមានសេចក្តីក្តុកក្តួលសោកស្តាយជាអតិបរមា ចំពោះការបាត់បង់រូបលោក **ស៊ីន ធន ឡឹប**ដែលជាថ្នាក់ដឹកនាំជាន់ខ្ពស់របស់សហគមន៍ខ្មែរកម្ពុជាក្រោម ជាវីរកុលបុត្រខ្មែរស្នេហាជាតិមួយរូបដ៏ឧត្តុងឧត្តម ជាពិសេសជាការបាត់បង់ឪពុក បាត់បង់ជីតាដែលប្រកបដោយគុណធម៌ដ៏ថ្លៃថ្លា។

លោក **ស៊ីន ធន ឡឹប** មិនថារស់នៅលើទឹកដីកម្ពុជាក្រោម ឬភៀសខ្លួនមករស់នៅប្រទេសអាមេរិកដែលជាប្រទេសមួយដ៏ទំនើបសម្បូរបែបនោះទេ លោកមិនដែលបំភ្លេចមាតុភូមិកំណើតរបស់ខ្លួនម្តងណាឡើយ ហើយតែងតែចូលរួមគ្រប់ចលនាតស៊ូក្នុងបុព្វហេតុជាតិ សាសនា និងមាតុភូមិខ្មែរ ជាពិសេសមាតុភូមិខ្មែរកម្ពុជាក្រោមជានិច្ច។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមវាយតម្លៃយ៉ាងខ្ពស់ និងមិនអាចបំភ្លេចបានចំពោះវីរភាពប្រកបដោយមនសិកាស្នេហាជាតិដ៏ខ្ពង់ខ្ពស់បំផុត និងស្នាដៃរាប់មិនអស់របស់លោកដែលបានបន្សល់ទុកជាប្រយោជន៍ដ៏ច្រើនដល់មាតុភូមិខ្មែរកម្ពុជាក្រោម ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមចូលរួមរំលែកមរណទុក្ខយ៉ាងក្រៀមក្រំ និងសោកស្តាយជាមួយក្រុមគ្រួសារសពលោក **ស៊ីន ធន ឡឹប** ដោយសេចក្តីគោរព និងស្មោះត្រង់ជាទីបំផុត ។

ដោយអំពើជាកុសលរបស់លោកដែលបានបំរើជាតិមាតុភូមិខ្មែរ និងព្រះពុទ្ធសាសនា សូមវិញ្ញាណក្ខន្ធរបស់លោកបានទៅសោយសុខក្នុងសុគតិភព កុំបីខាន ។

សូមជូនពរក្រុមគ្រួសារសពបានប្រកបទៅដោយពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមលោកស៊ីន ញឿន និងក្មួយប្រុស-ស្រីទាំងអស់ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំ។

*ភ្នំពេញ, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩*

**នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម**

**ថាច់ សេដ្ឋា**

សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ

អតីតសមាជិកព្រឹទ្ធសភា